**Declassified to Public**
**08 April 2021**

លេខ: D173/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-2016, 15:21
CMS/CFO: Sann Rada

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខៈ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៥**

ភាសា ៖ **អង់គ្លេស [ភាសាដើម ]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេត បញ្ជាក់បំភ្លឺថាតើ មេធាវីការពារក្តី អាចទាក់ទងជាមួយបុគ្គលនានា រួមទាំង សាក្សី អែម សុន បានដែរឬអត់

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម

Michael KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គីមសួន

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

សំ សុគង់

ទី ស្រ៊ីនណា

វ៉ែន ពៅ

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ និង ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត("ស.ច.ស") បានចុះបញ្ជីករណីខ្វែងយោបល់គ្នានៅក្នុងសំណុំរឿងនេះ។

២. នៅថ្ងៃទី ២៦,២៧, ២៨ និង ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ អ្នកស៊ើបអង្កេត Thomas Kuehnel បានស្តាប់ចម្លើយសាក្សីឈ្មោះ អែម សុន[1] យោងតាមការផ្ទេរអំណាចរបស់ ស.ច.ស.អន្តរជាតិ ដើម្បីបំពេញកិច្ចស៊ើបសួរ[2]។

៣. នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ មេធាវីការពារក្តីមាស មុត ("មេធាវីការពារក្តី") បានដាក់ *សំណើរបស់មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេតបញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តី អាចទាក់ទងជាមួយនឹងបុគ្គលទាំងឡាយ រួមទាំងសាក្សី អែម សុន បានឬយ៉ាងណា*("សំណើ")[3]។

## II. សារណា

៤. នៅក្នុងសំណើ មេធាវីការពារក្តី ស្នើសុំការបញ្ជាក់បំភ្លឺថាតើ ខ្លួនអាចទាក់ទងបុគ្គលនានា រួមទាំងសាក្សីនានា ឬសាក្សីសក្តានុពល *"ដើម្បីប្រមូលព័ត៌មានលម្អិតទូទៅ"*បានដែរឬអត់[4]។

---

[1]សំណុំរឿង ០០៣ ឯកសារ D54/46 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯម សុន ចុះថ្ងៃទី ២៦-១១-២០១៣* ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៣។ សំណុំរឿង ០០៣ ឯកសារ D54/47 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯម សុន ចុះថ្ងៃទី ២៧-១១-២០១៣* ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣។ សំណុំរឿង ០០៣ ឯកសារ D54/48 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯម សុន ចុះថ្ងៃទី ២៨-១១-២០១៣* ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៣។ សំណុំរឿង ០០៣ ឯកសារ D54/49 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯម សុន ចុះថ្ងៃទី ២៩-១១-២០១៣* ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

[2]សំណុំរឿង ០០៣ ឯកសារ D54 *ដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី ០៧-០២-២០១៣* ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ត្រូវបានពន្យារពេលអនុវត្តតាមរយៈឯកសារ D54.1 *អនុស្សរណៈរបស់ ស.ច.ស.អ ទាក់ទងនឹងការពន្យារពេលអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួសលេខ D54* ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣។

[3]សំណុំរឿង០០៣ ឯកសារD173 *សំណើរបស់មាស មុត សុំឲ្យសហចៅក្រមស៊ើបអង្កេតបញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តីអាចទាក់ទងជាមួយនឹងបុគ្គលទាំងឡាយ រួមទាំងសាក្សី អែម សុន បានឬយ៉ាងណា* ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

[4]សំណើ កថាខណ្ឌ ៧។

01187939



៥. មេធាវីការពារក្តី កត់សម្គាល់ថា ស.ច.ស និង អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានកំណត់ថា ភាគីនានា ត្រូវបានអនុញ្ញាតឲ្យធ្វើការស៊ើបសួរបឋម ហើយមេធាវីការពារក្តី បញ្ជាក់ថា វាសមហេតុផលក្នុងការសន្មតថា ការស៊ើបសួរបឋមបែបនេះអាចរាប់បញ្ចូលទាំងការទាក់ទងជាមួយបុគ្គលនានាដើម្បីប្រមូលព័ត៌មានលម្អិតទូទៅបែបនោះ[5]។

៦. មេធាវីការពារក្តី កត់សម្គាល់ថា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ("កិច្ចព្រមព្រៀង អ.វ.ត.ក") ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") និងវិធានផ្ទៃក្នុង មិនកំណត់និយមន័យអំពីអ្វីដែលជាកិច្ចស៊ើបសួរ ឬក៏ហាមឃាត់យ៉ាងច្បាស់លាស់មិនឲ្យភាគីទាក់ទងជាមួយបុគ្គលនានាដែរ[6]។

៧. មេធាវីការពារក្តី ស្នើសុំសាក្សី ឯម សុន ឲ្យនាំផ្លូវមេធាវីការពារក្តី ចុះទៅកោះតាង[7] និងស្នើសុំសាកសួរគាត់អំពី"*ព័ត៌មានលម្អិតទូទៅ*" និងសេចក្តីថ្លែងការណ៍ជាសាធារណៈដែលគាត់បានធ្វើឡើងទាក់ទងនឹងកោះតាង[8]។ មេធាវីការពារក្តី អះអាងថា ខ្លួនត្រូវតែធ្វើការស៊ើបសួរបែបនេះដើម្បីរៀបចំរឿងក្តីឲ្យបានហ្មត់ចត់ ដើម្បីផ្តល់ពន្លឺអំពីភស្តុតាងដោះបន្ទុកដែលអាចមានហើយ អាចស្នើ ស.ច.ស បំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធានផ្ទៃក្នុង ៥៥(១០)[9]។

---

[5]សំណើ កថាខណ្ឌ ៣។

[6]សំណើ កថាខណ្ឌ ២។

[7]ស.ច.ស ទទួលពិនិត្យការចោទប្រកាន់ដែលថា អ្នកទោសដែលត្រូវបានគេចាប់ខ្លួននៅម្តុំកោះតាង ត្រូវបានគេសម្លាប់តាមបញ្ជារបស់កងពល ១៦៤។ *សូមមើល* សំណុំរឿង ០០៣ ឯកសារ *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ជើងទំព័រ ៥៣។

[8]សំណើ កថាខណ្ឌ ៥។ មេធាវីការពារក្តី កត់សម្គាល់ថា ឯម សុន ត្រូវបានគេដកស្រង់សម្តីនៅក្នុងអត្ថបទពីរនាពេលថ្មីៗនេះ ហើយនៅក្នុងការស្តាប់ចម្លើយមួយរបស់ ក.ស.ច.ស គាត់បានបញ្ជាក់ថា គាត់ត្រូវបានគេសួរចម្លើយទាក់ទងនឹងសៀវភៅ និងភាពយន្តឯកសារមួយរឿង។ *សូមមើល* សំណើ ជើងទំព័រ ១៤។

[9]សំណើ កថាខណ្ឌ ៦។

## III. ពិភាក្សា

៨. ដូចដែលមេធាវីការពារក្តី បានកត់សម្គាល់[10] កិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ផ្តល់អំណាចបំពេញកិច្ចស៊ើបសួរឲ្យទៅ ស.ច.ស តែប៉ុណ្ណោះ[11]។ ជាពិសេស វិធានផ្ទៃក្នុង ៥៥(៥)(ក)ផ្តល់សិទ្ធិអំណាចឲ្យ ស.ច.ស ក្នុងការស្តាប់ចម្លើយសាក្សី និងបំពេញកិច្ចស៊ើបសួរចុះដល់ទីកន្លែង។ ស.ច.ស ធ្លាប់បានកត់សម្គាល់ថា វិធានផ្ទៃក្នុង ៥៥(៥)(ក)បង្ហាញយ៉ាងច្បាស់ថា សិទ្ធិអំណាចក្នុងការបំពេញមុខងារទាំងនេះគឺជា“*ដែនសមត្ថកិច្ចតែមួយគត់*”របស់ ស.ច.ស[12]។

៩. វិធានផ្ទៃក្នុង ៥៥(១០) ចែងអំពីតួនាទីរបស់ជនត្រូវចោទ ដែលអាចអនុញ្ញាតឲ្យមាននៅក្នុងការបំពេញកិច្ចស៊ើបសួរ គឺកម្រិតនៅត្រឹមស្នើ ស.ច.ស សុំបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ វិធានផ្ទៃក្នុង ៥៨(៦) បញ្ជាក់យ៉ាងច្បាស់ថែមទៀតអំពីសំណើអ្វីដែលជនត្រូវចោទ អាចស្នើបាន រាប់បញ្ចូលទាំងសំណើសុំ ស.ច.ស សាកសួរសាក្សី ឬចុះដល់ទីកន្លែងផងដែរ[13]។

១០. ដោយបានឃើញវិធានផ្ទៃក្នុងទាំងនេះ ស.ច.ស ធ្លាប់បានបញ្ជាក់ថាលទ្ធភាពរបស់ភាគីក្នុងការចូលពាក់ព័ន្ធក្នុងកិច្ចស៊ើបសួរ ត្រូវកម្រិតនៅត្រឹម *“ការស៊ើបសួរបឋមនេះដែលជាការចាំបាច់ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការស្នើសុំឲ្យមានកិច្ចស៊ើបសួរ”*[14]។ អ.ប.ជ បានបញ្ជាក់ពីការបកស្រាយវិធានផ្ទៃក្នុងបែបនេះ[15]។

---

[10]សំណើ កថាខណ្ឌ ២។

[11]មាត្រា ៥(១)នៃកិច្ចព្រមព្រៀង អ.វ.ត.ក។ មាត្រា ២៣ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ វិធានផ្ទៃក្នុង ៥៥(២)។

[12]សំណុំរឿង ០០២ ឯកសារ A110/I *ការឆ្លើយតបរបស់ ស.ច.ស ទៅនឹងលិខិតរបស់លោកមេធាវី នួន ជា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីកិច្ចស៊ើបអង្កេត* ថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៨ (“ការឆ្លើយតបរបស់ ស.ច.ស ទៅ នួន ជា”)ទំព័រ ១។

[13]នេះគឺស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលមាត្រា ១៣៣ ចែងថា *“ជនត្រូវចោទ អាចសុំឲ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង”*។

[14]ការឆ្លើយតបរបស់ ស.ច.ស ទៅ នួន ជា ទំព័រ ២។

[15]សំណុំរឿង ០០២ ឯកសារ D315/1/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស ចំពោះសំណើសុំរបស់លោក នួន ជា សុំឲ្យមានកិច្ចស៊ើបសួរទាក់ទងនឹងរដ្ឋបរទេស និងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើសុំបើកកិច្ចស៊ើបសួរពាក់ព័ន្ធនឹងរដ្ឋបរទេសចំពោះការទាត់ចោលសំណើសុំស្តាប់ចម្លើយសាក្សីដែលធ្វើឡើងដោយលោក ខៀវ សំផន* ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ (“សាលដីកាទាក់ទងនឹងរដ្ឋបរទេស”) កថាខណ្ឌ១៥។

១១. មេធាវីការពារក្តី ស្នើ ស.ច.ស សុំបញ្ជាក់បំភ្លឺអំពីភាពខុសគ្នារវាងកិច្ចស៊ើបសួរដែលត្រូវហាមឃាត់ និងកិច្ចស៊ើបសួរបឋមដែលត្រូវអនុញ្ញាត។ ទាំង ស.ច.ស ទាំង អ.ប.ជ បានផ្តល់ការណែនាំទាក់ទងនឹងភាពខុសគ្នានេះ ដោយបញ្ជាក់ថា ភាគីមានសេរីភាពត្រួតពិនិត្យប្រភពឯកសារសាធារណៈ[16] ដោយ អ.ប.ជ កត់សម្គាល់ថា ការស៊ើបសួរលើប្រភពមិនសាធារណៈអាចជាកិច្ចស៊ើបសួរដែលត្រូវហាមឃាត់[17]។ នៅក្នុងសេចក្តីសម្រេចដាច់ដោយឡែក អ.ប.ជ បានកត់សម្គាល់ថែមទៀតថា ភាគីអាចទាក់ទងរដ្ឋនានា ដើម្បីស៊ើបសួរអំពីអត្ថិភាពនៃឯកសារពាក់ព័ន្ធ ហើយស្វែងរកសំណៅនៃឯកសារបែបនោះ[18] ហើយ អ.ប.ជ បានលើកឡើងថា ការទាក់ទងបុគ្គលណាមួយដើម្បីសាកសួរថាតើគាត់ មានឯកសារឬអត់នោះ គឺជាការស៊ើបសួរបឋមដែលអាចអនុញ្ញាតបាន[19]។

១២. មេធាវីការពារក្តី លើកឡើងថា ការស្នើបុគ្គលណាម្នាក់ *"ឱ្យផ្តល់ព័ត៌មានលម្អិតទូទៅ"* គឺជាការស៊ើបសួរបឋមដែលអាចអនុញ្ញាតបាន ខុសពីការសួរសំណួរ *"បែបសារធាតុ"* ទៅសាក្សីដែលការសួរបែបនេះគឺជាកិច្ចស៊ើបសួរដែលត្រូវហាមឃាត់[20]។ ប៉ុន្តែ ការស៊ើបសួរបឋមដែលអាចអនុញ្ញាតបានដែល ស.ច.ស និង អ.ប.ជ លើកឡើង ត្រូវបានកម្រិតនៅត្រឹមការស៊ើបសួរដែលមានបំណងស្វែងរក និងត្រួតពិនិត្យឯកសារនានា គឺ ការត្រួតពិនិត្យឯកសារដែលអាច

---

[16]សំណុំរឿង ០០២ ឯកសារ D164/2 *ដីកាសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងទុកឯកសាររួម(SMD)* ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៤។ សំណុំរឿង ០០២ D365/2/10 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង* ថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ២០១០ ("សាលដីកាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ឯកសារភស្តុតាងបន្ថែម") កថាខណ្ឌ ១២។

[17]សាលដីកាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ឯកសារភស្តុតាងបន្ថែម កថាខណ្ឌ ១២។

[18]សាលដីកាទាក់ទងនឹងរដ្ឋបរទេស កថាខណ្ឌ ១៥។

[19]សំណុំរឿង ០០២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចលើសំណើលើកទី១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ២៩ (ដោយច្រានចោលបណ្តឹងឧទ្ធរណ៍របស់ នួន ជា ដែលថា ស.ច.ស បានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនស្វែងរកឯកសារពីបុគ្គលម្នាក់ ហើយ [អ.ប.ជ] ក៏បានកត់សម្គាល់ថា មេធាវីការពារក្តី នួន ជា *"មិនបានបង្ហាញថា ខ្លួនបានធ្វើកិច្ចស៊ើបសួរបឋម"*ថាតើបុគ្គលនោះមានឯកសារទាំងនោះឬអត់ទេ ")។

[20]សំណើ កថាខណ្ឌ ៥។

ទទួលបានជាសាធារណៈ ការស៊ើបសួរថាតើ រដ្ឋ និង/ឬបុគ្គលមានឯកសារពាក់ព័ន្ធដែរឬអត់ និង(យ៉ាងហោចណាស់ក្នុងករណីទាក់ទងនឹងរដ្ឋនានា) ស្វែងរកសំណៅនៃឯកសារបែបនោះ។ ចាំបាច់គឺថា ការស៊ើបសួរទាំងនេះត្រូវទាក់ទងនឹងសកម្មភាពរបស់មេធាវីការពារក្តី ដែលធ្វើឡើងក្នុងគោលបំណងជាបឋមដើម្បីជំរុញឱ្យ ស.ច.ស បំពេញកិច្ចស៊ើបសួរដោយផ្ទាល់ខ្លួន និងលម្អិត។ ម្យ៉ាងវិញទៀត ការសាកសួរសាក្សី និងការបំពេញកិច្ចចុះដល់ទីកន្លែងដូចដែលមេធាវីការពារក្តី បានរៀបរាប់ គឺជាកិច្ចស៊ើបសួររួចទៅហើយ ហើយការសាកសួរ និងការចុះដល់ទីកន្លែងកាន់តែច្រើន គឺកាន់តែចំណាយពេលយូរ ដូច្នេះជាទូទៅ កិច្ចស៊ើបសួរ បាននិងកំពុងបន្តដំណើរការ[21]។ មេធាវីការពារក្តី ទទួលស្គាល់ថា ជាឧទាហរណ៍ គោលបំណងនៃការចុះដល់ទីកន្លែងជាមួយសាក្សី ឯម សុន គឺដើម្បីប្រមូលព័ត៌មានអំពីទីកន្លែងមួយដែលអាចប្រើប្រាស់សម្រាប់ព័ត៌មានរួមថែមទៀតនៅក្នុងកិច្ចស៊ើបសួរ។ ការប្រមូលព័ត៌មានបែបនេះ ទោះបីជាចាត់ទុកថាមានគោលបំណងប្រមូលយកព័ត៌មានបែបពណ៌នាសុទ្ធសាធក៏ដោយ ក៏តាមខ្លឹមសារ គឺជាកិច្ចស៊ើបសួរដែរ គឺហួសពីការចុះដល់ទីកន្លែងជាធម្មតារបស់អ្នកស៊ើបអង្កេតនៅពេលដែលសាក្សីពណ៌នាអំពីទីកន្លែងណាមួយ និងអំពីអ្វីដែលមើលទៅដូចជានៅសម័យខ្មែរក្រហម។ ដូច្នេះ សំណើរបស់មេធាវីការពារក្តី សុំចុះដល់ទីកន្លែងដោយមានសាក្សីជាអ្នកនាំផ្លូវ ការសាកសួរសាក្សីអំពីទីកន្លែងណាមួយ និងការសាកសួរសាក្សីអំពីចម្លើយមុនៗរបស់គាត់ គឺជាសំណើដែលត្រូវហាមឃាត់។ ករណីនេះអនុវត្តដូចគ្នាទៅនឹងការទាក់ទងជនណាដែល ស.ច.ស មិនធ្លាប់បានទាក់ទងពីមុនមក។

១៣. ប្រសិនបើមេធាវីការពារក្តី យល់ឃើញថា ការចុះទៅកោះតាង ការសាកសួរសាក្សី ឯម សុន បន្ថែមទៀត ឬកិច្ចស៊ើបសួរណាមួយបន្ថែមទៀតមានប្រយោជន៍ដល់ការបំពេញកិច្ចស៊ើបសួរនោះ នីតិវិធីត្រឹមត្រូវគឺត្រូវដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធានផ្ទៃក្នុង ៥៥(១០) ដោយបញ្ជាក់ពីបញ្ហានានាដែលត្រូវស៊ើបអង្កេត។

១៤. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

[21] *សូមមើល* វិធានផ្ទៃក្នុង ៥៥(៥)(ក)។

01187943



**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

១៥. **ជូនដំណឹង** មេធាវីការពារក្តី ថា មេធាវីការពារក្តី មិនអាចបំពេញកិច្ចស៊ើបសួរបានទេ រាប់បញ្ចូលទាំងការសាកសួរសាក្សី ឯម សុន ដើម្បីប្រមូលព័ត៌មានលម្អិតទូទៅ ហើយក៏មិនអាចទាក់ទងជនណាដែលហួសពីដែនកំណត់យុត្តិសាស្ត្រពីមុនដូចបានរៀបរាប់ខាងលើ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៥

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**